ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ និងការប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣

កាលពីថ្ងៃអង្គារ ១៤រោច ខែមាឃ ដល់ថ្ងៃព្រហស្បតិ៍ ២កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៥-៧ ខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ និងការប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ សរុបប្រមាណ ៥០០នាក់។ ក្នុងរយៈពេល ៣ថ្ងៃនេះ អង្គសន្និបាតបានធ្វើបទបង្ហាញ និងពិភាក្សាលើប្រធានបទជាអាទិភាពកំណែទម្រង់ទាំង៥ ដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ២០១៤-២០១៨ ដូចខាងក្រោម៖

## ក- លទ្ធផលការងារឆ្នាំ២០១៨

### ១-ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

- បានបន្តតាមដានការអនុវត្តអនុសាសន៍១០ចំណុច របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ប្រកបដោយជោគជ័យ។
- បានធ្វើអធិការកិច្ចការងារចំនួន ៩ ៣៥០លើក, បានដាក់កំហិតចំនួន ១ ០៥១សហគ្រាស, បានដាកពិន័យ ១០០សហគ្រាស និងប្តឹងទៅតុលាការ ៤សហគ្រាស។
- បានផ្សះផ្សាវិវាទការងារសរុបចំនួន ៥៨០ករណី ដោយសះជាចំនួន ២៩៦ករណី, មិនសះជាចំនួន ២២៤ករណី និងមោឃៈចំនួន ៦០ករណី ក្នុងនោះវិវាទការងាររួមចំនួន ១៦៣ករណី នៃ ១២៥សហគ្រាស (កម្មករនិយោជិត ៩៣ ៥២១នាក់)។ សំណុំរឿងដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានមានចំនួន ៥៣ករណី បានចេញសេចក្តីបង្គាប់ចំនួន ៤១ករណី និងសះជា១២ករណី។
- បានពង្រឹងការអនុវត្តច្បាប់ស្តីពីសហជីព ដោយក្នុងឆ្នាំ២០១៨ នេះ បានចុះបញ្ជីសហជីពមូលដ្ឋានចំនួន ៤៨៩, សហព័ន្ធសហជីពចំនួន ៣៧, សហភាពសហជីពចំនួន៤ និងសមាគមនិយោជក



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨៤ ៣៧៥ និងទូរសារៈ(០២៣)៨៨ ២៧ ៦៥

ចំនួន ៣។ គិតមកដល់ពេលនេះ ក្រសួងបានចុះបញ្ជីអង្គការវិជ្ជាជីវៈ សរុបចំនួន ៤ ៨៣៨ ក្នុងនោះ សហជីពមូលដ្ឋានចំនួន ៤ ៦២១, សហព័ន្ធសហជីពចំនួន ១៨០, សហភាពសហជីពចំនួន ២៨ និងសមាគមនិយោជកចំនួន ៩។

- បានដោះស្រាយបញ្ហាកូដកម្មចំនួន ៤៧ករណី (សះជា ១០០%, ថយចុះ ៥១,៥%) មានកូដករសរុប ១០ ៨៩០នាក់ (ថយចុះ ៦៦,១% ធៀបនឹងឆ្នាំ២០១៧)។ បានអន្តរាគមន៍លើបាតុកម្មចំនួន ៥ករណី (សះជា ១០០%, ថយចុះ ៩៤,៤%), មានបាតុករចំនួន ៤៨៦នាក់ (ថយចុះ ៩១,៤% ធៀបនឹងឆ្នាំ២០១៧)។

- បានផ្តល់សេវាពិនិត្យកាយសម្បទាជូនកម្មករនិយោជិត សរុបចំនួន ៣៤០ ៨៤៨នាក់ (ស្រី ១៧៩ ៦៨១នាក់) កើនឡើង ១៤,៥% ធៀបនឹងឆ្នាំ២០១៧។

- បានផ្តល់បណ្ណ និងសៀវភៅការងារដល់កម្មករនិយោជិតខ្មែរចំនួន ២៨១ ០៥២នាក់ និងជនបរទេសចំនួន ១៣៥ ២០១នាក់។

- បានដំឡើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងពី ១៧០ដុល្លារអាមេរិក ដល់ ១៨២ដុល្លារអាមេរិកក្នុង១ខែ សម្រាប់ឆ្នាំ២០១៩ បូករួមប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗអាចទទួលបានប្រាក់ឈ្នួលចាប់ពី ១៩៩ដុល្លារអាមេរិក ដល់ ២១០ដុល្លារអាមេរិកក្នុង១ខែ។ ក្រសួងក៏បានរៀបចំច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាដែលបានធ្វើសមាហរណកម្មគោលការណ៍សិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិស្តីពី ការពង្រឹងដំណើរការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា កាលពីឆ្នាំ២០១៤ ទៅជាច្បាប់ និងបង្កើតក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដែលមានសមាសភាពត្រីភាគីស្មើៗគ្នា។

- បានបន្តជំរុញដល់ម្ចាស់សហគ្រាស គ្រឹះស្ថាននានា អនុញ្ញាតឱ្យបងប្អូនកម្មការិនីមានផ្ទៃពោះចាប់ពី ៣ខែឡើង ចេញមុនម៉ោងយ៉ាងតិច ១៥នាទី និងអនុញ្ញាតឱ្យបងប្អូនកម្មករនិយោជិតជាស្ត្រីខ្មែរឥស្លាម អាចប្រើប្រាស់សម្លៀកបំពាក់តាមប្រពៃណីឥស្លាម។

- បានជំរុញគ្រប់រោងចក្រត្រូវរៀបចំបន្ទប់បំបៅកូន សម្រាប់កម្មការិនីដែលមានកូនក្រោមអាយុ ១២ខែ និងត្រូវមានទារកដ្ឋានសម្រាប់កម្មការិនីដែលមានកូនអាយុលើស ១៨ខែ។ គ្រប់តំបន់សេដ្ឋកិច្ចពិសេស ឬសួនឧស្សាហកម្មត្រូវរៀបចំឱ្យមានទារកដ្ឋានមួយក្នុងតំបន់របស់ខ្លួន។

- បានដាក់ចេញវិធានការដោះស្រាយទប់ស្កាត់ករណីដួលសន្លប់ ដោយតម្រូវឱ្យគ្រប់រោងចក្រ សហគ្រាសទាំងអស់ ពិនិត្យលក្ខណៈបច្ចេកទេស លំហូរខ្យល់ និងស្ថានភាពជុំវិញរោងចក្រឱ្យមានសុវត្ថិភាពមុនពេលចូលធ្វើការ។

- បានបន្តសហការជាមួយក្រសួងពាក់ព័ន្ធដោះស្រាយបញ្ហាសុវត្ថិភាពក្នុងការដឹកជញ្ជូន និងការធ្វើដំណើររបស់បងប្អូនកម្មករនិយោជិត តាមរយៈការរៀបចំកែសម្រួលមធ្យោបាយដឹកជញ្ជូន ពង្រឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

- បានបន្តរៀបចំកម្មវិធីសំណេះសំណាលរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាមួយបងប្អូនប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម និងបងប្អូនកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធចាប់ពីថ្ងៃ

អាទិត្យ ទី២០ ខែសីហា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ បានចំនួន ៦៤លើក មានកម្មករនិយោជិតសរុបចំនួន ៩១៧ ៧១២នាក់។

**២-ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- បានផ្សព្វផ្សាយអំពីគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ដល់ភាគីពាក់ព័ន្ធនានា ដើម្បីជំរុញការអភិវឌ្ឍជំនាញនៅកម្ពុជា។
- បានបន្តជំរុញកម្មវិធីផ្សព្វផ្សាយ តាមរយៈការរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ កាលពីថ្ងៃទី១៥-១៦ ខែមិថុនា ឆ្នាំ២០១៨ និងការផ្សព្វផ្សាយថ្នាក់ខេត្ត ដែលមានអ្នកចូលរួមសរុបចំនួន ៨២ ៦១៤នាក់ (ស្រី ៤៤ ៩៣៩នាក់)។
- បានអភិវឌ្ឍកញ្ចប់ស្តង់ដាផ្អែកលើសមត្ថភាព (គុណវុឌ្ឍជាតិកម្រិត១ ២ ៣ និងកម្រិត៤) ក្នុងវិស័យសំណង់ អគ្គិសនី និងវិស័យកម្មន្តសាលចំនួន ០៦មុខរបរ ដែលមាន ១២គុណវុឌ្ឍ។
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈថ្មីចំនួន ០៣ បានទទួលវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដា ISO 9001-2015។
- បានបើកវគ្គវិក្រឹត្យការគ្រូបច្ចេកទេសនៅតាមសហគ្រាសចំនួន ១០៥នាក់ និងជ្រើសរើសនិងបណ្តុះបណ្តាលគ្រូបច្ចេកទេសថ្មីចំនួន ២៩៦នាក់។
- បានចុះធ្វើអធិការកិច្ច និងវាយតម្លៃគ្រូបច្ចេកទេសនៅតាមគ្រឹះស្ថានសិក្សាចំនួន ១៥គ្រឹះស្ថាន។
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ និងឯកជនចំនួន ១០៦ បានធ្វើការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ៖
    - រយៈពេលខ្លី (ក្រោម ១ឆ្នាំ) ចំនួន ៣៦ ៣៦៦នាក់ (ស្រី ២០ ៤៥៤នាក់) និងកម្មវិធីស្ពានចម្លងបន្តជំនាញចំនួន ២ ៥២១នាក់ (ស្រី ៨០២នាក់)
    - រយៈពេលវែង (១ឆ្នាំឡើង) សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ ៣ សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស និងបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ ចំនួន ១៣ ៣១៤នាក់ (ស្រី ៤ ៤៦២នាក់)
- បានចុះធ្វើអធិការកិច្ចហ្វឹកហ្វឺនកូនជាងចំនួន ៥៣១សហគ្រាស, បានហ្វឹកហ្វឺនកូនជាងចំនួន ២៧ ៧០០នាក់ (ស្រី ១៩ ៨៤៦នាក់), ធ្វើតេស្តកូនជាងចប់ការហ្វឹកហ្វឺនចំនួន ១០ ៨៩៧នាក់ (ស្រី ៧ ៧៥៩នាក់)។
- បានបញ្ជូនបេក្ខជនចូលរួមប្រកួតប្រជែងជំនាញអាស៊ានលើកទី១២ នៅប្រទេសថៃចំនួន ១២នាក់ ដោយទទួលបានវិញ្ញាបនបត្រល្អប្រសើរចំនួន ០២នាក់។

**៣-ការអភិវឌ្ឍមុខរបរ និងការងារ**

- បានបង្កើតការងាររហូតជាង ៤,៨លាននាក់ ក្នុងនោះ នៅក្នុងប្រទេសប្រមាណ ៣,៦លាននាក់ (ផ្នែកសេដ្ឋកិច្ចក្នុងប្រព័ន្ធមានចំនួនជាង ១,៤លាននាក់ និងផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រមាណ ២,២លាននាក់) និងពលករដែលធ្វើការនៅក្រៅប្រទេសមានចំនួនប្រមាណជាង ១,២លាននាក់។
- ប្រជាពលរដ្ឋមានការងារធ្វើជាង ៩៩,៣% នៃកម្លាំងពលកម្មសរុបជិត ១០លាននាក់។

- សហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបចំនួន ១២ ៧៩៦សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចំនួន ១ ៤២០ ៥៤៧នាក់ និងបានទទួលប្រាក់ឈ្នួលជាមធ្យមសរុបជិត ៣ប៊ីលានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ សហគ្រាស គ្រឹះស្ថានផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបចំនួន ២៣ មានកម្មករនិយោជិតចំនួន ១២៤ ៩៤៦នាក់។ ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ បានដើរតួនាទីយ៉ាងសកម្មក្នុងការបំពេញឱ្យគ្នាទៅវិញទៅមករវាងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងបានរួមវិភាគទានយ៉ាងធំក្នុងសេដ្ឋកិច្ចជាតិប្រមាណជាង ៦ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។
- បានផ្តល់ឱកាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋបានចំនួន ១ ២៣៥ ៩៩៣នាក់ (ស្រី ៤៩៩ ០៧០នាក់) ក្នុងនោះ៖
  - ប្រទេសថៃមានចំនួន ១ ១៤៦ ៦៨៥នាក់ (ស្រី ៤៥៨ ០២៧នាក់) ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាចំនួន ៣០៥បាត ទៅ ៣១០បាត ក្នុង១ថ្ងៃ ឬប្រហាក់ប្រហែលនឹង ៣០០ ដុល្លារអាមេរិកក្នុង១ខែ។ រាជរដ្ឋាភិបាលកម្ពុជា និងថៃ បានសម្រេចជោគជ័យនូវយុទ្ធនាការផ្តល់ភាពស្របច្បាប់ ជូនពលករកម្ពុជាដែលកំពុងធ្វើការនៅប្រទេសថៃប្រមាណ ១,០៧លាននាក់ ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។
  - សាធារណរដ្ឋកូរ៉េមានចំនួន ៤៩ ០៩៩នាក់ (ស្រី ១០ ៤០៣នាក់) ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាជាង ៥ ០០០វ៉ុន ក្នុង១ម៉ោង ឬប្រហាក់ប្រហែលនឹង ១ ២០០ដុល្លារអាមេរិកក្នុង១ខែ។
  - ប្រទេសជប៉ុនមានចំនួន ៩ ១៩៥នាក់ (ស្រី ៣ ៨៦៧នាក់) ដោយទទួលបានប្រាក់ឈ្នួលជាមធ្យមប្រមាណជា ១ ៥០០ដុល្លារអាមេរិកក្នុង១ខែ។
  - ប្រទេសម៉ាឡេស៊ីមានចំនួន ៣០ ១១៣នាក់ (ស្រី ២៥ ៨៧២នាក់) ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាប្រមាណ ៣០០ដុល្លារអាមេរិកក្នុង១ខែ។
  - ប្រទេសសឹង្ហបុរី មានចំនួន ៨៣១នាក់ (ស្រី ៨៣១នាក់) ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាប្រមាណ ៤៥០ដុល្លារអាមេរិកក្នុង១ខែ។
  - តំបន់រដ្ឋបាលពិសេសហុងកុង ទើបចាប់ផ្តើមបញ្ជូនពលការិនីបានចំនួន ៥៤នាក់ ដោយទទួលបានប្រាក់ឈ្នួល ៥៥០ដុល្លារអាមេរិកក្នុង១ខែ។ ចាប់ពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ទទួលបានប្រាក់ឈ្នួល ៥៧៨ដុល្លារអាមេរិកក្នុង១ខែ។
  - ព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត ទើបចាប់ផ្តើមបញ្ជូនពលការិនីបានចំនួន១៦នាក់ ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាប្រមាណ ៣០០ដុល្លារអាមេរិកក្នុង១ខែ។

ជារួមក្នុងមួយឆ្នាំៗ ពលករទេសន្តរប្រវេសន៍ខ្មែរបានផ្ញើថវិកាជូនក្រុមគ្រួសារបានប្រមាណជាង ២,៣ ប៊ីលានដុល្លារអាមេរិក ព្រមទាំងទទួលបាននូវមុខជំនាញវិជ្ជាជីវៈពេលត្រលប់មកវិញ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។ ជាមួយគ្នានេះ ពេលពលករទៅធ្វើការនៅក្រៅប្រទេសទទួលបានភាពអនុគ្រោះ ដោយមិនបាច់បង់ថ្លៃលើលិខិតធ្វើដំណើរ ទទួលបាននូវការគាំពារតាមផ្លូវច្បាប់ និងអន្តរាគមន៍សង្គ្រោះនៅពេលមានហានិភ័យជាយថាហេតុ និងការយកចិត្តទុកដាក់ តាមរយៈការជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ ការរៀបចំពិធីផ្សេងៗ និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ទាំងមុនចេញដំណើរ និងពេលមានកម្មវិធីបុណ្យប្រពៃណីជាតិខ្មែរនៅឯមូលដ្ឋានការងាររបស់បងប្អូនពលករយើងថែមទៀតផង។

- បានប្រមូលចុះឈ្មោះអ្នកស្វែងរកការងារចំនួន ១៦ ៥២៧នាក់ បានផ្សព្វផ្សាយព័ត៌មានអំពីឱកាសការងារចំនួន ៨៣ ៥៣៨នាក់ និងជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋតាមមូលដ្ឋានភូមិឃុំ និងតាមរយៈវេទិកាការងារនានាដែលរៀបចំដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ និងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់។
- បានផ្តល់មគ្គុទេសក៍ក្នុងការរៀបចំផែនការអាជីព និងជ្រើសរើសជំនាញសិក្សាដល់សិស្សមធ្យមសិក្សាទុតិយភូមិតាមរយៈសិក្ខាសាលាចំនួន ២៤៣ដង ដែលមានសិក្ខាកាមសរុប ១២ ៩៨៦នាក់។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការតម្រង់ទិសវិជ្ជាជីវៈ នៅតាមវិទ្យាល័យ អនុវិទ្យាល័យ ក្នុងរាជធានី ខេត្ត មានអ្នកចូលរួមសរុប ៥៥ ១៦១នាក់ (ស្រី ២៦ ២៤៩ នាក់)។
- បានបន្តអនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ និងសម្របសម្រួលផ្តល់ភាពស្របច្បាប់ដល់ពលករដែលមិនទាន់ស្របច្បាប់ ដើម្បីធានានូវផលប្រយោជន៍ស្របច្បាប់ តាមរយៈទីប្រឹក្សាការងារអមស្ថានឯកអគ្គរាជទូតកម្ពុជានៅប្រទេសថៃ កូរ៉េ ម៉ាឡេស៊ី និងជប៉ុន។

**៤-ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ**

- បានអនុវត្តរបបហានិភ័យការងារចំនួនសរុប ៩ ៥០១សហគ្រាស គ្រឹះស្ថាន មានកម្មករនិយោជិត ១ ២០២ ៣៩៨នាក់ កើនឡើង ៤,៣% ធៀបនឹងឆ្នាំ២០១៧។ បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារចំនួន ៣២ ៣៦៨ឯកសារ ដោយចំណាយថវិកាអស់ ២០,១៦ប៊ីលានរៀល កើនឡើង ៥,៣% ធៀបនឹងឆ្នាំ២០១៧។
- បានអនុវត្តរបបថែទាំសុខភាព (ប.ស.ស) ដោយបានចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញបានចំនួន ៩ ៥០១សហគ្រាស គ្រឹះស្ថាន មានកម្មករនិយោជិត ១ ២០២ ៣៩៨នាក់។
- បានចុះបញ្ជីរបបថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនបានចំនួន ៣២ ក្រសួង-ស្ថាប័ន មានសមាជិកសរុបចំនួន ៣១២ ៣០៦នាក់ និងមានអ្នកទៅប្រើសេវាចំនួន ២៥ ៨៥១ដង/នាក់ និងចំណាយថវិកាសរុបចំនួន ២,៤៨ប៊ីលានរៀល។
- បានផ្តល់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈបានចំនួន ២៥ ៨៥១ដង/នាក់ ក្នុងនោះ សម្រាលកូនបានចំនួន ៩០៥នាក់។
- បានផ្តល់របបសន្តិសុខសង្គមដល់ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន ៩៤១សហគ្រាស គ្រឹះស្ថាន មានកម្មករសរុប ចំនួន ៧៧ ៩១៨នាក់។
- បានកំណត់ឱ្យនិយោជកជាប់កាតព្វកិច្ចបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព១00% ជំនួសកម្មករនិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨ មានចំនួន ៩ ០៩៣សហគ្រាស គ្រឹះស្ថាន មានកម្មករនិយោជិតជាង១ ៣៤៧ ០០៤នាក់។

- បានអនុវត្តកម្មវិធីផ្ដល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីសម្រាលកូនចំនួន ៦៥ ០៥៤នាក់ ចំនួនកូន ៦៥ ៥៣៤នាក់ កូនភ្លោះ២ចំនួន ៩៤០នាក់ និងកូនភ្លោះ៣ចំនួន ១៥នាក់ ដែលបានផ្ដល់ប្រាក់ឧបត្ថម្ភសរុបចំនួនប្រមាណជិត ៦លាន ៦សែនដុល្លារអាមេរិក។

- បានអនុវត្តកម្មវិធីផ្ដល់ការពិនិត្យព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាល ដែលបានចុះបញ្ជីជាមួយ ប.ស.ស ទាំងអស់ដោយមិនបង់ថ្លៃសម្រាប់កម្មករនិយោជិតបាន ២ ៤៥១ ៥៤៥ដង/នាក់ ចំណាយថវិកាចំនួន ២៨៨,៧៧ប៊ីលានរៀល។

- បានសិក្សាស្រាវជ្រាវ និងកំពុងរៀបចំយន្តការដាក់ឱ្យដំណើរការនូវរបបប្រាក់សោធននៅឆ្នាំ២០១៩ នេះ។

- បាននិងកំពុងសហការជាមួយបណ្ដាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបប្រាក់សោធន ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយបន្ទាប់ពីចប់កិច្ចសន្យាការងារ ដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធន។

**៥-ការពង្រឹងអភិបាលកិច្ចល្អ**

- បានពង្រឹងការគ្រប់គ្រងថវិកា និងបានបើកប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាន់ពេល និងតាមប្រព័ន្ធធនាគារ ១០០%។

- បានអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ" ដោយរៀបចំថវិកាកម្មវិធីសម្រាប់អនុវត្តយុទ្ធសាស្ត្រអាទិភាព និងកំណែទម្រង់ទាំង៥ នៃការអភិវឌ្ឍវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០១៤-២០១៨ សម្រាប់អនុវត្តឆ្នាំ២០១៨។

- បានរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល, ផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ, របាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ, របាយការណ៍វាយតម្លៃលទ្ធផលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨, ផ្ដល់ធាតុចូលក្នុងការកសាងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (SDGs), ផ្ដល់ធាតុចូលក្នុងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនានា និងបានរៀបចំរបាយការណ៍ស្ដីពីលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០១៤-២០១៨។

- បានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអគ្គាធិការកិច្ច ដោយបង្កើតយន្តការសម្របសម្រួលផ្ទៃក្នុងចុះបេសកកម្មតែមួយ តែរបាយការណ៍ផ្សេងគ្នា និងបានខិតខំលើកកម្ពស់សមភាពយេនឌ័រស្របតាមផែនការយុទ្ធសាស្ត្រស្ដីពីនារីរតនៈទី៣ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ២០១៤-២០១៨។

- បានបន្តកិច្ចសហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ដោយបង្កើតគណៈកម្មការជាតិ និងលេខាធិការដ្ឋាននៃគណៈកម្មការជាតិត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្ដល់សច្ចាប័ន។

- បានអនុម័តផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តអនុសាសន៍របស់អង្គការ ILO ពាក់ព័ន្ធនឹងសេរីភាពអង្គការវិជ្ជាជីវៈ និងបានផ្សព្វផ្សាយដល់គ្រប់សមាជិក នៃគណៈកម្មការជាតិនេះ ក្រោមកិច្ចសហការត្រីភាគី និងជំនួយបច្ចេកទេសពីអង្គការ ILO ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ។
- បានធ្វើរបាយការណ៍ឆ្លើយតបទៅអង្គការ ILO ចំនួន ១១ និងរបាយការណ៍ពាក់ព័ន្ធកិច្ចការអាស៊ានចំនួន ១២។

**ខ. ទិសដៅអនុវត្តបន្តឆ្នាំ២០១៩**

១-បន្តខិតខំអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ទាំង ១០ចំណុច របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីគាំពារ និងសម្រួលដល់បន្ទុកចំណាយ ក៏ដូចជាដោះស្រាយបញ្ហានានារបស់បងប្អូនកម្មករនិយោជិត។

២-បន្តសិក្សាស្រាវជ្រាវលទ្ធភាពធ្វើវិសោធនកម្មច្បាប់ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិ និងលក្ខខណ្ឌការងារស្របតាមតម្រូវការសង្គម សេដ្ឋកិច្ច។

៣-ពង្រឹងគុណភាព និងប្រសិទ្ធភាពអធិការកិច្ចការងារ ដោយដាក់ឱ្យប្រើប្រាស់របាយការណ៍អធិការកិច្ចការងាររួម លើប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្មដែលអាចធ្វើការសំយោគ និងវាយតម្លៃលក្ខខណ្ឌការងារដោយស្វ័យប្រវត្តិ។

៤-កែសម្រួលវិធីសាស្ត្រចុះធ្វើអធិការកិច្ចការងារ ដោយផ្អែកលើកម្រិតហានិភ័យរបស់សហគ្រាស គ្រឹះស្ថាន និងកំណត់ការធ្វើអធិការកិច្ចការងារលើសហគ្រាស គ្រឹះស្ថាននាំចេញចំនួន ១លើក/ឆ្នាំ។

៥-ប្រកាសកំណត់លក្ខខណ្ឌការងារស្នូល ៣១ចំណុច និងលក្ខខណ្ឌការងារទូទៅ ៤១ចំណុច ដែលសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្ត។

៦-បន្តពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ ដោយបង្កើតឱ្យមានគ្រូបង្គោលលើវិស័យការងារយ៉ាងតិចចំនួន ៥០នាក់ និងធ្វើវិក្រឹត្យការដល់មន្ត្រីអធិការកិច្ចការងារយ៉ាងតិចចំនួន ៤៥០នាក់ ជាមួយនឹងការប្រឡងបញ្ជាក់សមត្ថភាពក្រោយពេលវគ្គវិក្រឹត្យការ។

៧-ផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារជាពិសេសអំពីសិទ្ធិការងារ ដល់ប្រតិភូបុគ្គលិក/ប្រតិភូសហជីព/ថ្នាក់ដឹកនាំសហជីពយ៉ាងតិចចំនួន ១ ២០០នាក់ និងដល់បុគ្គលិករដ្ឋបាលនៃសហគ្រាស គ្រឹះស្ថានយ៉ាងតិចចំនួន ៧៥០នាក់។

៨-បន្តសហការជាមួយគម្រោងកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC), គម្រោងបទដ្ឋានសង្គម និងការងារក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរនៅទ្វីបអាស៊ី (GIZ, SLSG) នៅប្រទេសកម្ពុជា និងគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងជាសកលរបស់ស៊ុយអ៊ែត។

៩-បន្តទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃកម្លាំងពលកម្មកុមារ និងការងារដោយបង្ខំ។

១០-បន្តខិតខំដោះស្រាយវិវាទការងារជូនដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ដោយសិក្សាជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបញ្ចូលការដោះស្រាយវិវាទបុគ្គលមួយចំនួនជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រមទាំងខិតខំទប់ស្កាត់ការធ្វើកូដកម្ម បាតុកម្មខុសច្បាប់ ដោយឈរលើគោលការណ៍ច្បាប់ និងនីតិរដ្ឋ។

១១-ជំរុញប្រែក្លាយសហគ្រាស គ្រឹះស្ថានមួយជាសហគមន៍សុខសាន្តមួយរបស់កម្មករនិយោជិតដែលពោរពេញដោយសមត្ថភាព ផលិតភាព ឥរិយាបថការងារ និងមនសិការវិជ្ជាជីវៈខ្ពស់។

១២-រៀបចំកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព (CBT) ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត ១ ២ ៣ ៤ លើវិស័យអគ្គិសនី/អេឡិចត្រូនិក (២មុខរបរ/៣គុណវុឌ្ឍិ) មេកានិករថយន្ត (៤មុខរបរ/៦គុណវុឌ្ឍិ) សំណង់ (៣មុខរបរ/៥គុណវុឌ្ឍិ) និងវិស័យធុរកិច្ច/ព័ត៌មានវិទ្យា (១មុខរបរ/២គុណវុឌ្ឍិ) សរុប១០មុខរប/១៦គុណវុឌ្ឍិ។

១៣-បង្កើនចំនួនសិស្សទទួលបានសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើជំនាញអាទិភាព៖

- រយៈពេលខ្លី (ក្រោម ១ឆ្នាំ) យ៉ាងតិចចំនួន ២៧ ០០០នាក់
- រយៈពេលវែង (១ឆ្នាំឡើង) សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១,២,៣ យ៉ាងតិចចំនួន ៤ ០៥០នាក់ សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស យ៉ាងតិចចំនួន ៥ ៥០០នាក់ និងបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ យ៉ាងតិចចំនួន ៦ ០០០នាក់ ដែលនឹងកើនឡើង ២០% ជារៀងរាល់ឆ្នាំ

១៤-រៀបចំយន្តការ និងកម្មវិធីបណ្តុះបណ្តាលជំនាញឡើងវិញ (Reskilling) និងយន្តការជាមួយដៃគូពាក់ព័ន្ធដើម្បីផ្តល់ឥណទានដល់ សិក្ខាកាម សិស្ស និស្សិត ដែលបញ្ចប់វគ្គបណ្តុះបណ្តាលដើម្បីបង្កើតមុខរបរខ្លួនឯង។

១៥-កែសម្រួលលិខិតបទដ្ឋានដែលផ្តល់ភាពស្មើគ្នារវាងកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងកាតព្វកិច្ចហ្វឹកហាត់ការងារ/កម្មសិក្សា និងពង្រឹងការហ្វឹកហ្វឺនកូនជាង និងកម្មសិក្សា និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

១៦-ពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងធ្វើសមាហរណកម្មកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ និងកម្មវិធីរបស់ដៃគូអភិវឌ្ឍ។

១៧-បន្តលើកកម្ពស់ការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាពដោយពង្រីកយន្តការ "វេទិកាការងារ" ព្រមទាំងការជំរុញកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់កម្លាំងពលកម្មជាមួយបណ្តាប្រទេសដៃគូ ជាពិសេសបង្កើតសេវាគាំទ្រដល់ពលករទេសន្តរប្រវេសន៍ខ្មែរ សំដៅធានាបាននូវការគាំពារពលករទេសន្តរប្រវេសន៍ខ្មែរ និងក្រុមគ្រួសារ។

១៨-បន្តពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងការរៀបចំការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននៅឆ្នាំ២០១៩ ពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ពង្រីកការអនុវត្តប្រកាសអន្តរក្រសួងស្តីពីការអនុវត្តការថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិត ជាស្ត្រីនៅពេលសម្រាលកូន។

១៩-បង្កើនការអប់រំ ការផលិតស្ពតអប់រំ និងការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍ ដើម្បីបង្ការទប់ស្កាត់គ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ និងការដួលសន្លប់។

២០-បន្តការអនុវត្តផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តអនុសាសន៍របស់អង្គការ ILO ពាក់ព័ន្ធនឹងសេរីភាពអង្គការវិជ្ជាជីវៈ ដើម្បីជំរុញការលើកកម្ពស់ការអនុវត្តសេរីភាពអង្គការវិជ្ជាជីវៈនៅកម្ពុជា។

២១-ពង្រឹងសមត្ថភាពមន្ត្រី និងអង្គភាពក្នុងការផ្តល់សេវាសាធារណៈនានា ប្រកបដោយភាពទន់ភ្លន់ ក្រមសីលធម៌វិជ្ជាជីវៈ និងទាន់ពេលវេលាជូនប្រជាពលរដ្ឋ ជាពិសេសកម្មករនិយោជិត ស្របតាមគោលការណ៍ វិមជ្ឈការ និងវិសហមជ្ឈការ។

២២-កសាងឱ្យបាននូវប្រព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុ ប្រកបដោយតម្លាភាព គណនេយ្យភាព និងការត្រួតពិនិត្យវាយតម្លៃមួយត្រឹមត្រូវ និងទៀងទាត់ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តអភិក្រមទាំង៥ គឺ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ និងបាវចនាកែទម្រង់ផ្ទៃក្នុង របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

២៣-ជំរុញ និងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ-វិស័យឯកជន (Public-Private Partnership) ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ស្របតាមបាវចនា បង្កើនមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

២៤-រៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងាររបស់គ្រប់អង្គភាពក្រោមឱវាទក្រសួង ដោយបង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ២កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩